ក្រុងភ្នំពេញ ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះ ។

សេចក្តីសំរេចនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និងចុះហត្ថលេខាតទៅ ។

សហប្រធាន

រដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា

ព្រះហស្ថលេខា ហត្ថលេខា

ស្តេចក្រុមហ្លួង នរោត្តម រណឫទ្ធិ ហ៊ុន សែន

* * *

ភ្នំពេញ, ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ១៩៩៣

## សេចក្តីសំរេច លេខ ១៩ សសរ
## ស្តីពីការបង្កើតលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ សំរាប់និតិសម្បទា និង អភិវឌ្ឍន៍ នៃប្រទេសកម្ពុជា

x x x

## រដ្ឋាភិបាលជាតិបណ្តោះអាសន្ន នៃកម្ពុជា

- បានឃើញក្រឹត្យ ស្តីពីការតែងតាំងរដ្ឋាភិបាលជាតិបណ្តោះអាសន្ន នៃកម្ពុជា របស់សម្តេចព្រះឧបយុវរាជ នរោត្តម សីហនុ ព្រះប្រមុខរដ្ឋ នៃកម្ពុជា ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣
- បានឃើញសេចក្តីសំរេចរបស់រដ្ឋាភិបាលជាតិបណ្តោះអាសន្ន នៃកម្ពុជា ស្តីពីការបង្កើតគណៈកម្មាធិការជាតិសំរាប់និតិសម្បទា និងអភិវឌ្ឍន៍ ( ហៅកាត់ថា គ ជ ន ) នៃប្រទេសកម្ពុជា លេខ ០៨ សសរ ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៩៩៣

តាមសំណើរបស់ គ.ជ.ន

- តាមសំណើរបស់ គ ជ នា

## សំរេច

**ប្រការ ១** : បង្កើតលេខាធិការដ្ឋានរបស់គណៈកម្មាធិការជាតិសំរាប់ទិតិសម្បទា និង អភិវឌ្ឍន៍ ( ហៅកាត់ថាលេខាធិការដ្ឋាន គ ជ នា ) នៃប្រទេសកម្ពុជាដែលមានទីតាំងនៅក្រសួងផែនការ ក្រោមការគ្រប់គ្រង នៃឯកឧត្តមរដ្ឋមន្ត្រីក្រសួងផែនការ ។ ឯកឧត្តម ឡាយ ព្រះហស្ត អនុរដ្ឋមន្ត្រីក្រសួងផែនការ និង ទទួលការគ្រប់គ្រងនេះជំនួសមុខអោយរដ្ឋមន្ត្រីក្រសួងផែនការ ។

**ប្រការ ២** : សមាសភាពគណៈដឹកនាំរបស់លេខាធិការដ្ឋាន គ ជ នា មានដូចខាងក្រោម :

១- លោក ឃើវ ណាំ នាយកដ្ឋានសហប្រតិបត្តិការជាមួយបរទេស ជាលេខាធិការប្រតិបត្តិ
២- លោក ស៊ុំ សន្តិសីទ នាយកដ្ឋានផែនការទូទៅ ជាសមាជិក
៣- លោក ឃើវ លឹមហ៊ាង នាយកដ្ឋានផែនការវិនិយោគសាធារណៈ ជាសមាជិក
៤- លោកស្រី ច័ន្ទ សូរិយ៍ ជំនួយលេខាធិការនៃ គ ជ នា ជាសមាជិកា
៥- លោកស្រី ឈួរ អាយ តំណាងក្រសួងការបរទេស ជាសមាជិកា
៦- លោក ឈឹម សុវណ្ណ តំណាងក្រសួងហិរញ្ញវត្ថុ ជាសមាជិក

**ប្រការ ៣** : លេខាធិការដ្ឋាន គ ជ នា ជាសេនាធិការអចិន្ត្រៃយ៍របស់គណៈកម្មាធិការ គ ជ នា ដើម្បីប្រមូលផ្តុំ និង សំរបសំរួលការងារជាមួយបណ្តាក្រសួង និង ស្ថាប័ននានាលើគ្រប់បញ្ហាទាំងអស់ដែលពាក់ព័ន្ធនឹងភារកិច្ចរបស់ គ ជ នា ។

លេខាធិការដ្ឋាននេះ ប្រើប្រាស់មន្ត្រីទីចាត់ការ បុគ្គលិក កម្មករ របស់នាយកដ្ឋានសហប្រតិបត្តិការជាមួយបរទេស ជាជំនួយការដោយសហការជាមួយនាយកដ្ឋាននានាក្នុងក្រសួងផែនការ ដើម្បីអនុវត្តបណ្តាភារកិច្ចសំខាន់ ៗ ដូចខាងក្រោម ÷

១- រៀបចំឯកសារ ផ្តល់ឯកសារ និង ព័ត៌មាន សហការជាមួយស្ថាប័ន ក្រសួងនានាអំពីបញ្ហាដែលពាក់ព័ន្ធនឹងការលើក គម្រោងនិងរៀបចំគំរោងនានា ស្តីពីការស្នើ និង រៀបចំទទួលជំនួយពីបរទេសជូន គ ជ នា ពិនិត្យ ។

២- សហការជាមួយស្ថាប័នជំនាញដែលពាក់ព័ន្ធធ្វើការតាមដាន ការអនុវត្តន៍ ធ្វើការបូកសរុប និង រៀបចំធ្វើរបាយការណ៍តាមកាលកំណត់ជូន គ ជ នា ដើម្បីរាយការណ៍

៣- រៀបចំកម្មវិធីដើម្បីដាក់ផ្លូវគំរោងការងារនីតិសម្បទា និង អភិវឌ្ឍន៍ ជារួមជាដោយឡែក តាមវិស័យ តាមផ្នែក ព្រមទាំងធ្វើរបាយការណ៍ផ្សេងៗ ជូន គ ជ ន ។

៤- ក្នុងករណីមានការលើកឡើង ដើម្បីអនុវត្តគំរោងការងារដែលពាក់ព័ន្ធនឹង គ ជ ន លេខាធិការដ្ឋានមានភារកិច្ច សហការជាមួយក្រសួងជំនាញ ដើម្បីពិភាក្សាវាយតំលៃ និង ជ្រើសរើសក្រុមហ៊ុនឯកជនក្នុង និងក្រៅប្រទេសដែលបានដាក់ពាក្យលើកឡើងទាំងនោះ ។

៥- លេខាធិការដ្ឋាននេះ មានទំនាក់ទំនងសហការផ្ទាល់ជាមួយលេខា គណៈកម្មាធិការ គ ជ ន ។ លេខាធិការដ្ឋាននេះ មានក្រុមការងារ ០២ ជាសំខាន់ :

ក. ផ្នែកទទួលបន្ទុកសំរបសំរួល និង ពិភាក្សាជាមួយស្ថាប័នផ្តល់ជំនួយអន្តរជាតិ

ខ. ផ្នែកសំរបសំរួលជាមួយបណ្តាក្រសួងមានសមត្ថកិច្ច ដើម្បីលើកសំណើ និង ចាត់ចែងអនុវត្តគំរោងការងារនានាអោយមានប្រសិទ្ធភាព ។

៦- ចងក្រង និង ថែរក្សាឯកសាររបស់ គ ជ ន ។

ប្រការ ៤ : លេខាធិការដ្ឋានរបស់គណៈកម្មាធិការជាតិសំរាប់នីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជាក្នុងករណីចាំបាច់អាចអញ្ជើញតំណាងស្ថាប័នក្រសួងនានានិង អ្នកឯកទេសមកពិគ្រោះ ពិភាក្សា និង ផ្តល់យោបល់លើគំរោងនានាដែលពាក់ព័ន្ធទៅនឹងការស្តារនិងអភិវឌ្ឍន៍ប្រទេសកម្ពុជា ។

ប្រការ ៥ : ក្នុងករណីចាំបាច់ ដើម្បីដំណើរការក្នុងអង្គភាព លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសំរាប់នីតិសម្បទា និង អភិវឌ្ឍន៍ នៃកម្ពុជា អាចបង្កើតក្រុមការងារ និង ផ្នែកផ្សេងៗទៀតនាពេលខាងមុខ ។

ប្រការ ៦ : លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសំរាប់នីតិសម្បទា និង អភិវឌ្ឍន៍កម្ពុជា ត្រូវរៀបចំគំរោងសម្ភារៈចាំបាច់សំរាប់បំរើការងារនៅក្នុងលេខាធិការដ្ឋាន ។

ប្រការ ៧ : រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ ក្រសួងការបរទេស ក្រសួងហិរញ្ញវត្ថុ និង សាមីខ្លួនត្រូវអនុវត្តសេចក្តីសំរេចនេះអោយបានមុឺងម៉ាត់ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ឧបនាយករដ្ឋមន្ត្រី និង សហប្រធាន

គណៈកម្មាធិការជាតិសំរាប់នីតិសម្បទា និងអភិវឌ្ឍន៍នៃប្រទេសកម្ពុជា

ហត្ថលេខា ហត្ថលេខា

គាត ឈន់ ហ៊ុន សែន